ជូនចំពោះម្ចាស់អាជីវករទាំងអស់

# ការណែនាំអំពីប្រព័ន្ធធានារ៉ាប់រងប្រាក់សោធននិវត្តន៍សុខុមាលភាព និងធានារ៉ាប់រងសុខភាព

## ការចូលធានារ៉ាប់រងប្រាក់សោធននិវត្តន៍សុខុមាលភាព(ណេនគីន) និងធានារ៉ាប់រងសុខភាព គឺជាការគាំទ្រជីវភាពរស់នៅរបស់បុគ្គលិកទាំងអស់គ្នា។




បែបបទនៃការចុះឈ្មោះចូលធានារ៉ាបរង ក៏ដូចជាការពិគ្រោះយោបល់ សូមទៅកាន់ការិយាល័យប្រាក់សោធននិវត្តន៍ជិតលោកអក




គេហទំព័រសេវាកម្មសោធននិវត្តន៍ជប៉ុន HTTPS://WWW.NENKIN.GO.JP/

សេវាកម្មប្រាក់សោធននិវត្តន៍ជប៉ុន ទទួលបន្ទុកលើការងារចាត់ចែងប្រាក់សោធននិវត្តន៍សាធារណៈ។

日本年金機構
Japan Pension Service

2009 1017 074

# អំពីកាតព្វកិច្ចចូលធានារ៉ាប់រង

កន្លែងអាជីវកម្មដូចខាងក្រោម មានកាតព្វកិច្ចចូលធានារ៉ាប់រងណេនគីន និងធានារ៉ាប់រងសុខភាពដែលកំណត់ដោយច្បាប់។

(កន្លែងអាជីវកម្មមានលក្ខណៈបង្ខំ)

**កន្លែងអាជីវកម្ម នីតិបុគ្គលទាំងអស់**
(អ្នកមានធានារ៉ាប់រងពី 1 រូបឡើង)



**កន្លែងអាជីវកម្មបុគ្គល**
(ផ្តល់ការងារដល់បុគ្គលិកពេញសិទ្ធិចាប់ពី 5 រូបឡើង)



※ ទោះជាកន្លែងអាជីវកម្មនីតិបុគ្គលក្តី ចំពោះនីតិបុគ្គលគ្រឹះស្ថានសិក្សាគឺត្រូវចូលក្នុងប្រព័ន្ធជួយគ្នាទៅវិញទៅមករបស់បុគ្គលិកសាលារៀនឯកជន។

※ ទោះជាកន្លែងអាជីវកម្មបុគ្គលមានបុគ្គលិក 5 នាក់ក្តី ចំពោះកន្លែងអាជីវកម្មសេវាកម្មមួយផ្នែក កសិកម្មនិងព្រៃឈើ ជលផល ចិញ្ចឹមសត្វ និងច្បាប់ជាដើមត្រូវបានលើកលែងពីកន្លែងអាជីវកម្មដែលមានលក្ខណៈបង្ខំ។

ទោះជាកន្លែងអាជីវកម្មក្រៅពីកន្លែងអាជីវកម្មដែលត្រូវអនុលោមតាមបង្ខំក្តី ប្រសិនបើគ្រប់លក្ខខណ្ឌចាំបាច់ នោះអាចចូលធានារ៉ាប់រងណេនគីន និងធានារ៉ាប់រងសុខភាពបាន។ (កន្លែងអាជីវកម្មដែលត្រូវអនុលោមតាមយល់ព្រមប៉ុណ្ណោះ)

# អ្វីទៅជាអ្នកទទួលធានារ៉ាប់រង

ចំពោះធានារ៉ាប់រងណេនគីន និងធានារ៉ាប់រងសុខភាព គឺកន្លែងអាជីវកម្មអនុលោមដោយឯកតាក្រុមហ៊ុន (កន្លែងអាជីវកម្ម) ហើយអ្នកត្រូវជួលនៅកន្លែងអាជីវកម្មនោះទាំងអស់ជាអ្នកទទួលធានារ៉ាប់រង។

※ ធានារ៉ាប់រងណេនគីន ជាគោលការណ៍គឺត្រូវចូលរហូតដល់អាយុ 70 ឆ្នាំ។




## លក្ខខណ្ឌចូលធានារ៉ាប់រងណេនគីន និងធានារ៉ាប់រងសុខភាព

បុគ្គលិកពេញសិទ្ធិ តំណាង និងថ្នាក់ដឹកនាំក្រុមហ៊ុនជាដើម គឺជាអ្នកទទួលធានារ៉ាប់រង។

បុគ្គលិកបណ្តោះអាសន្ន និងអ្នកធ្វើការតាមម៉ោងក៏ដោយ ឲ្យតែធ្វើការលើសពី 3/4 នៃបុគ្គលិកពេញសិទ្ធិនៅកន្លែងការងារដូចគ្នា និងក្នុងចំនួនម៉ោងនៃការងារដែលកំណត់តាម 1 សប្តាហ៍ ក៏ដូចចំនួនថ្ងៃការងារកំណត់ក្នុង 1 ខែ គឺជាអ្នកទទួលធានារ៉ាប់រង។

ម្យ៉ាងទៀត ទោះជាតិចជាង 3/4 នៃបុគ្គលិកពេញសិទ្ធិ ឲ្យតែបំពេញលក្ខខណ្ឌកំណត់មួយដូចជា ក្នុង១សប្តាហ៍ធ្វើការច្រើនជាង 20 ម៉ោង ក៏ជាអ្នកទទួលធានារ៉ាប់រងដែរ។




## ករណីផ្តល់ការងារដល់អ្នកទទួលប្រាក់សោធននិវត្តន៍

ករណីផ្តល់ការងារដល់អ្នកទទួលប្រាក់សោធននិវត្តន៍ចាស់ជរាក្រោម 70 ឆ្នាំ (រួមទាំងអ្នកទទួលពិសេស) ក៏ដោយ អ្នកដែលបំពេញលក្ខខណ្ឌចូល គឺជាអ្នកទទួលធានារ៉ាប់រង។

ប៉ុន្តែ ក្នុងពេលបំពេញការងារ ប្រាក់សោធននិវត្តន៍សុខុមាលភាពចាស់ជរា មានករណីដែលការផ្អាកប្រាក់សោធននិវត្តន៍មួយផ្នែកឬទាំងអស់ត្រូវបានបញ្ឈប់ ដោយផ្អែកទៅលើចំណូលសរុបក្នុង 1 ខែក្រោយគណនាចេញពីប្រាក់ខែ ប្រាក់រង្វាន់ និងប្រាក់សោធននិវត្តន៍។

## ករណីផ្តល់ការងារដល់ជនបរទេស

អ្នកដែលបំពេញលក្ខខណ្ឌចូល គឺជាអ្នកទទួលធានារ៉ាប់រង ដោយមិនគិតពីសញ្ជាតិឡើយ។

## ការចាត់ចែងធានារ៉ាប់រងសង្គមក្នុងរយៈពេលសាកល្បង

ដោយមិនអាស្រ័យទៅលើកិច្ចសន្យាការងារនៅក្នុងច្បាប់ ឬការយល់ព្រមពីសាមីខ្លួននោះ ឲ្យតែអ្នកនោះបានបំពេញលក្ខខណ្ឌចូល គឺជាអ្នកទទួលធានារ៉ាប់រងចាប់ពីការចាប់ផ្តើមរយៈពេលសាកល្បងនោះ។

2009 1017 074

# បែបបទនៃការដាក់ពាក្យ

នៅពេលចូលធានារ៉ាប់រងណេនគីន និងធានារ៉ាប់រងសុខភាព ចាំបាច់ត្រូវដាក់ពាក្យតាមរយៈម្ចាស់អាជីវកម្ម។



នៅពេលកន្លែងអាជីវកម្មជាអ្នកចូល

**បែបបទបំពេញលក្ខខណ្ឌថ្មី**



នៅពេលចូលជាអ្នកទទួលធានារ៉ាប់រង

**បែបបទទទួលបានលក្ខណៈសម្បត្តិជាអ្នកទទួលធានារ៉ាប់រង**



នៅពេលអ្នកកទទួលធានារ៉ាប់រងមានអ្នកនៅក្នុងបន្ទុក

**បែបបទអ្នកក្នុងបន្ទុក(ផ្ទេរ)**

**※ នីតិវិធីដាក់ពាក្យលម្អិតឬសំណុំឯកសារចាំបាច់ សូមសួររកនៅការិយាល័យប្រាក់សោធននិវត្តន៍។**

ជាមួយនេះ ក៏អាចទាញយកឯកសារដាក់ពាក្យពីគេហទំព័ររបស់សេវាកម្មប្រាក់សោធននិវត្តន៍ជប៉ុនបានដែរ។ HTTPS://WWW.NENKIN.GO.JP/

# អត្ថប្រយោជន៍នៃធានារ៉ាប់រងណេនគីន

ធានារ៉ាប់រងណេនគីន គឺជាប្រព័ន្ធផ្ដល់ប្រាក់សោធននិវត្តន៍ ឬប្រាក់ផ្ដល់តែម្ដង តាមរយៈការស្នើសុំ នៅពេលអ្នកទទួលចាស់ជរា ជួបគ្រោះថ្នាក់ ឬពេលស្លាប់។

## នៅពេលចាស់ជរា <ប្រាក់សោធននិវត្តន៍សុខុមាលភាពចាស់ជរា>

អ្នកដែលបានចូលធានារ៉ាប់រងណេនគីន នៅពេលបំពេញលក្ខខណ្ឌខាងក្រោម
អាចផ្ដល់ប្រាក់សោធននិវត្តន៍សុខុមាលភាពចាស់ជរា ទៅតាមប្រាក់សោធនមូលដ្ឋានចាស់ជរា។

**① លើស 65 ឆ្នាំ (ចាប់ពី 60 ឆ្នាំឡើង អាចទទួលមុន ឬ ចាប់ពី 66 ឆ្នាំឡើង អាចទទួលយឺតបាន)**
**② រយៈពេលអ្នកទទួលធានារ៉ាប់រងណេនគីន គឺពី១ខែឡើង**
**③ ដើម្បីទទួលប្រាក់សោធនមូលដ្ឋានចាស់ជរា មានរយៈពេលលក្ខខណ្ឌចាំបាច់**

| 60 ឆ្នាំ | 65 ឆ្នាំ |
|---|---|
| ប្រាក់សោធនសុខុមាលភាពចាស់ជរាផ្ដល់ពិសេស | ប្រាក់សោធនសុខុមាលភាពចាស់ជរា |
| | ប្រាក់សោធនមូលដ្ឋានចាស់ជរា |

ម្យ៉ាងទៀត ពីអាយុ 60 ដល់ 65 ឆ្នាំ អ្នកដែលបំពេញល/ខខាងក្រោម អាចផ្ដល់ប្រាក់សោធនសុខុមាលភាពចាស់ជរាដោយផ្ដល់ពិសេសបាន។
(ផ្អែកតាមថ្ងៃខែឆ្នាំកំណើត និងភេទ អាយុចាប់ផ្ដើមផ្ដល់ខុសគ្នា។)

**① 60 ឆ្នាំឡើង**
**② រយៈពេលទទួលធានារ៉ាប់រងណេនគីន ចាប់ពី 1 ឆ្នាំឡើង**
**③ មានរយៈពេលគុណសម្បត្តិដែលចាំបាច់សម្រាប់ទទួលប្រាក់សោធនមូលដ្ឋានចាស់ជរា**

## នៅពេលធ្លាក់ក្នុងស្ថានភាពគ្រោះថ្នាក់ <ប្រាក់សោធនសុខុមាលភាពគ្រោះថ្នាក់>

ក្នុងពេលចូលធានារ៉ាប់រងណេនគីន នៅពេលជួបគ្រោះថ្នាក់ ដោយសារឈឺ ឬរបួស អាចទទួលការផ្គត់ផ្គង់តាមស្ថានភាពនោះ នៅថ្ងៃចូលព្យាបាលដំបូង(ថ្ងៃចូលមន្ទីរពេទ្យដំបូង)

**※ ចាំបាច់ត្រូវមានរយៈពេលបង់ថ្លៃធានារ៉ាបរងចាប់ពីកម្រិតកំណត់ឡើងទៅ។**

| ប្រាក់ | កម្រិតគ្រោះថ្នាក់ |
|---|---|
| ប្រាក់សោធនសុខុមាលភាពគ្រោះថ្នាក់ / ប្រាក់សោធនមូលដ្ឋានគ្រោះថ្នាក់ | **កម្រិតគ្រោះថ្នាក់ កម្រិត 1～2** ផ្ដល់ទាំងប្រាក់សោធនសុខុមាលភាពគ្រោះថ្នាក់ និងប្រាក់សោធនមូលដ្ឋានគ្រោះថ្នាក់។ |
| ប្រាក់សោធនសុខុមាលភាពគ្រោះថ្នាក់ | **កម្រិតគ្រោះថ្នាក់ កម្រិត 3** ផ្ដល់តែប្រាក់សោធនសុខុមាលភាពគ្រោះថ្នាក់។ |
| ប្រាក់ឧបត្ថម្ភគ្រោះថ្នាក់ | **កម្រិតគ្រោះថ្នាក់ គ្រោះថ្នាក់ស្រាលជាងកម្រិត 3** ផ្ដល់ប្រាក់ឧបត្ថម្ភគ្រោះថ្នាក់ជាប្រាក់ឧបត្ថម្ភតែ១លើក។ |

## នៅពេលស្លាប់ <ប្រាក់សោធនសុខុមាលភាពក្រុមគ្រួសារអ្នកស្លាប់>

នៅពេលស្លាប់ក្នុងអំឡុងពេលចូលធានារ៉ាប់រងណេនគីន(រួមទាំងការស្លាប់ ដោយសារជំងឺក្នុងពេលកំពុងចូលធានារ៉ាប់រង ដោយគិតចាប់ពីថ្ងៃព្យាបាលដំបូង រហូតដល់ប្រាំឆ្នាំ) ធានារ៉ាប់រងសុខុមាលភាពសាច់ញាតិនឹងផ្ដល់ទៅ**<u>ក្រុមគ្រួសារអ្នកស្លាប់ដែលត្រូវបានថែរក្សាកន្លងមក។</u>**

**※ ចាំបាច់ត្រូវមានរយៈពេលបង់ថ្លៃធានារ៉ាបរងចាប់ពីកម្រិតកំណត់ឡើងទៅ។**

- សាច់ញាតិដែលប្រាក់សោធនសាច់ញាតិត្រូវផ្ដល់ អ្នកដែលមានលំដាប់សាច់ញាតិខ្ពស់ (មានលក្ខខណ្ឌអាយុ។)

①ប្ដីឬប្រពន្ធ ឬកូន → ②ឪពុកម្ដាយ → ③ ចៅ → ④ជីដូនជីតា

- ចំពោះប្ដីឬប្រពន្ធមានកូន ឬកូន ផ្ដល់រួមជាមួយប្រាក់សោធនមូលដ្ឋានសាច់ញាតិ។ (មានលក្ខខណ្ឌអាយុ។)

| ប្ដីឬប្រពន្ធមានកូន ឬកូន | សាច់ញាតិផ្សេងទៀត |
|---|---|
| ប្រាក់សោធនសុខុមាលភាពសាច់ញាតិ | ប្រាក់សោធនសុខុមាលភាពសាច់ញាតិ |
| ប្រាក់សោធនមូលដ្ឋានសាច់ញាតិ | |

# អត្ថប្រយោជន៍ធានារ៉ាប់រងសុខភាព

ធានារ៉ាប់រងសុខភាព ជាប្រព័ន្ធផ្តល់ការព្យាបាលឬប្រាក់ឧបត្ថម្ភ តាមរយៈការដាក់ពាក្យស្នើសុំ នៅពេលអ្នកទទួលធានារ៉ាប់រង ឬគ្រួសារ(អ្នកក្នុងបន្ទុក)មានជំងឺ ឬរបួស(លើកលែងនៅពេលធ្វើការងារនិងគ្រោះថ្នាក់ពេលទៅបំពេញការងារ)។

<table>
<tr><th></th><th></th><th>អ្នកទទួលធានារ៉ាប់រង</th><th>អ្នកក្នុងបន្ទុក</th></tr>
<tr><td rowspan="4">ជំងឺ<br>របួស</td><td>ពេលព្យាបាលដោយបង្ហាញប័ណ្ណអ្នកទទួលធានារ៉ាប់រង</td><td colspan="2">អាចទទួលការព្យាបាលចាំបាច់ដោយបង់ថ្លៃមួយចំណែក នៅបញ្ជរនៃមន្ទីរព្យាបាលដែលទទួលយកធានារ៉ាប់រងសុខភាព។</td></tr>
<tr><td>នៅពេលថ្លៃព្យាបាលថ្លៃខ្ពស់</td><td colspan="2">នៅពេលលបង់ថ្លៃព្យាបាលមួយចំណែកដែលហួសកម្រិតកំណត់ នៅពេលទទួលការព្យាបាលនៅមន្ទីរព្យាបាល អាចស្នើសុំសំណងបាន។ ម្យ៉ាងទៀត តាមរយៈការទទួលប័ណ្ណសម្គាល់ អាចកាត់បន្ថយបន្ទុកនៅបញ្ជរ។</td></tr>
<tr><td>នៅពេលព្យាបាលក្រៅប្រទេស</td><td colspan="2">នៅពេលទៅកំសាន្តឬទៅការងារនៅក្រៅប្រទេស ហើយត្រូវទទួលការព្យាបាលនៅមន្ទីរព្យាបាលទីនោះដោយខានមិនបាន អាចទទួលសំណងមួយផ្នែកបាន ដោយគិតតាមមូលដ្ឋានតម្លៃនៃការព្យាបាលនៅជប៉ុន។</td></tr>
<tr><td>នៅពេលសម្រាកពីការងារដោយជំងឺ ឬរបួស</td><td>នៅពេលពុំមានប្រាក់ខែ អាចទទួលប្រាក់ឧបត្ថម្ភរបួស និងជំងឺ។</td><td></td></tr>
<tr><td rowspan="2">សម្រាលកូន</td><td>នៅពេលសម្រាលកូន</td><td colspan="2">នៅពេលសម្រាលកូនដោយមានផ្ទៃពោះលើសពី៤ខែ(៨៥ថ្ងៃ) អាចទទួលថវិកាសម្រាលនិងថែទាំកូន១លើក។</td></tr>
<tr><td>នៅពេលសម្រាកពីការងារ ដោយមាតុភាព</td><td>នៅពេលពុំមានប្រាក់ខែ អាចទទួលប្រាក់ឧបត្ថម្ភមាតុភាព។</td><td></td></tr>
<tr><td>មរណភាព</td><td>នៅពេលស្លាប់</td><td colspan="2">នៅពេលស្លាប់ដោយមូលហេតុក្រៅពីពេលបំពេញការងារនិងគ្រោះថ្នាក់ពេលទៅការងារ មានការឧបត្ថម្ភថ្លៃបញ្ចុះសព។</td></tr>
</table>

**※ ដើម្បីទទួលបានការផ្តល់ធានារ៉ាប់រងសុខភាព ត្រូវមានលក្ខខណ្ឌមួយចំនួន។**

ការស្នើសុំផ្តល់ធានារ៉ាប់រងសុខភាព ក៏ដូចការពិគ្រោះយោបល់ សូមសួររកនៅសាខាខេត្តនីមួយៗរបស់សមាគមធានារ៉ាប់រងសុខភាពទូទាំងប្រទេស។
ខ្លឹមសារផ្តល់លម្អិត និងពាក្យសុំ ក៏ដូចបែបបទនានា មានបង្ហោះនៅលើគេហទំព័ររបស់សមាគមធានារ៉ាប់រងសុខភាពទូទាំងប្រទេស (HTTPS://WWW.KYOUKAIKENPO.OR.JP/) ។ សូមមើលនៅទីនោះ។

# វិធីគណនាថ្លៃធានារ៉ាប់រង

ថ្លៃធានារ៉ាប់រងសម្រាប់ធានារ៉ាប់រងណេនគីន និងធានារ៉ាប់រងសុខភាព កំណត់ជាមូលដ្ឋានដោយផ្អែកលើប្រាក់ខែដែលអ្នកទទួលធានារ៉ាប់រងទទួលបាន
គណនាដោយយកប្រាក់ខែគុណនឹងអត្រាថ្លៃធានារ៉ាប់រងដូចខាងក្រោម។
ម្យ៉ាងទៀត ចំពោះប្រាក់រង្វាន់ គឺយកប្រាក់រង្វាន់ស្តង់ដារគុណនឹងអត្រាថ្លៃធានារ៉ាប់រងដូចថ្លៃធានារ៉ាប់រងប្រចាំខែ។

### ■ ប្រាក់ខែស្តង់ដារ

○ ធានារ៉ាប់រងណេនគីន
កម្រិត1(88,000 យ៉េន)~កម្រិត32(650,000យ៉េន)

○ ធានារ៉ាប់រងសុខភាពគ្រប់គ្រងដោយសមាគមធានារ៉ាប់រងសុខភាពទូទាំងប្រទេស
កម្រិត1(58,000 យ៉េន)~កម្រិត50(1,390,000 យ៉េន)

### ■ ប្រាក់រង្វាន់ស្តង់ដារ

ជាប្រាក់ដែលគិតពីប្រាក់រង្វាន់ដែលទទួលបាន ដោយកាត់យកឯកតា 1000 យ៉េន។

### ■ អត្រាថ្លៃធានារ៉ាប់រង (ចំពោះអត្រាថ្លៃធានារ៉ាប់រង អាចការកែប្រែថ្ងៃក្រោយ។)

○ ធានារ៉ាប់រងណេនគីន
183.00 ភាគ 1000

○ ធានារ៉ាប់រងសុខភាពគ្រប់គ្រងដោយសមាគមធានារ៉ាប់រងសុខភាពទូទាំងប្រទេស
កំណត់តាមខេត្តនីមួយៗ។ ព័ត៌មានលម្អិត សូមសួរនៅសាខាខេត្តនីមួយៗរបស់សមាគមធានារ៉ាប់រងសុខភាពទូទាំងប្រទេស។

○ ប្រាក់ឧបត្ថម្ភកុមារនិងការថែទាំកុមារ
3.6ភាគ1000 (ជាបន្ទុករបស់ម្ចាស់អាជីវកម្មទាំងអស់)

ថ្លៃធានារ៉ាប់រងជាបន្ទុករបស់ម្ចាស់អាជីវកម្ម និងអ្នកទទួលធានារ៉ាប់រងពាក់កណ្តាលម្នាក់ ដោយម្ចាស់អាជីវកម្មជាអ្នកប្រមូលបង់ទៅឲ្យការិយាល័យសោធននិវត្តន៍។
ប៉ុន្តែចំពោះប្រាក់ឧបត្ថម្ភកុមារនិងការថែទាំកុមារ ម្ចាស់អាជីវកម្មទទួលបន្ទុកទាំងអស់ ដោយទុកជាផ្នែកមួយនៃការចំណាយចាំបាច់សម្រាប់ឧបត្ថម្ភកុមារ។
(អ្នកទទួលធានារ៉ាប់រងមិនមានបន្ទុកទេ។)
ព័ត៌មានលម្អិត សូមពិគ្រោះយោបល់នៅការិយាល័យប្រាក់សោធននិវត្តន៍។

2009 1017 074